# សិទ្ធិផ្តាច់មុខនិងផលវិបាក ក្នុងកម្មសិទ្ធិបញ្ញា

ដោយ ពេជ អង្គ, ស្ថាបនិកនិងអតីតប្រធានសមាគមកម្មសិទ្ធិបញ្ញាកម្ពុជា ភ្នាក់ងារម៉ាក មេធាវី

angpich.lawyer@gmail.com Telegram 012 73 97 73

PICH & PARTNERS
Law & Intellectual Property

# ១.អ្វីជាសិទ្ធិផ្តាច់មុខ?

I. ប្រើប្រាស់ ធ្វើអាជីវកម្ម ចាត់ចែង អនុញ្ញាត លើសិទ្ធិរបស់ខ្លួន

II. ហាមឃាត់ការប្រើប្រាស់ ឬការរំលោភបំពាន និងប្តឹងទៅតុលាការ ឬស្ថាប័នមានសមត្ថកិច្ច

PICH & PARTNERS
Law & Intellectual Property

# ៧.ការទទួលបានសិទ្ធិផ្តាច់មុខ *(Exclusive right)*

ម្ចាស់កម្មសិទ្ធិបញ្ញាមានសិទ្ធិផ្តាច់មុខ៖

- ម៉ាក៖ ចុះបញ្ជី ឬដោយភាពល្បីដោយការប្រើប្រាស់
- ប្រកាសនីយប័ត្រតក្កកម្ម៖ ដោយការចុះបញ្ជី
- គំនូរឧស្សាហកម្ម៖ ដោយការចុះបញ្ជី
- សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល៖ ដោយការបង្កើតស្នាដៃ (ចុះបញ្ជី)

អ្នកដែលមិនមែនជាម្ចាស់កម្មសិទ្ធិបញ្ញាអាចទទួលសិទ្ធិផ្តាច់មុខពីម្ចាស់កម្មសិទ្ធិបញ្ញា តាមរយៈកិច្ចសន្យាអាជ្ញាបណ្ណ កិច្ចសន្យាចែកចាយ ឬកិច្ចសន្យាហ្វ្រែនឆាយ ឬការផ្ទេរកម្មសិទ្ធិបញ្ញា

# សិទ្ធិផ្តាច់មុខក្នុងច្បាប់ម៉ាក

**មាត្រា ១១.-**

សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក មានដូចខាងក្រោម :

ក- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬសេវា ដែលបានចុះបញ្ជីរួចហើយ ការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើម ត្រូវមានការយល់ព្រមពីម្ចាស់ដើមជាមុនសិន ។

ខ- ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការ ប្រឆាំងនឹងជនណាម្នាក់ ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម ។ ម្ចាស់ដើមក៏មានសិទ្ធិប្តឹងផងដែរចំពោះការប្រើប្រាស់នូវសញ្ញា ដែលប្រហាក់ប្រហែលនឹងម៉ាកដែលខ្លួនបានចុះបញ្ជី រួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវា ដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយ នោះហើយដែលអាចបណ្តាលឱ្យមានការភ័ន្តច្រឡំជាសាធារណៈ ។

# សិទ្ធិផ្តាច់មុខក្នុងច្បាប់ប្រកាសនីយប័ត្រតក្កកម្ម

**មាត្រា ៤១.-**

ការធ្វើអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជានូវតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ ដោយបុគ្គលដទៃទៀត ចាំបាច់ត្រូវតែមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មនោះ ។

**មាត្រា ៤២.-**

ក្នុងន័យនៃច្បាប់នេះ ការធ្វើអាជីវកម្មនៃតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ គឺមានន័យថា ជាសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយខាងក្រោមនេះ :

១- ចំពោះផលិតផលមួយ ដែលបានផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មរួចហើយ ការធ្វើអាជីវកម្មគឺជា :

ក- ការផលិត ការនាំចូល ការផ្គត់ផ្គង់សម្រាប់ការលក់ និងការប្រើប្រាស់ផលិតផលនោះ

ខ- ការស្តុកទុកផលិតផលនោះ ក្នុងគោលបំណងផ្គត់ផ្គង់សម្រាប់លក់ ឬប្រើប្រាស់

- ចំពោះដំណើរការផលិតកម្មមួយ ដែលបានផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មរួចហើយ អាជីវកម្មគឺជា :

ក- ការប្រើប្រាស់ដំណើរការផលិតកម្មនោះ

ខ- ការធ្វើសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយ ដូចមាន
ងក្នុងចំណុច ក និងចំណុច ខ នៃចំណុចទី ១ នៃមាត្រានេះ លើផលិតផលដែល ទទួលបានដោយ
ធ្យោបាយនៃដំណើរការផលិតកម្មនោះ ។

# សិទ្ធិផ្តាច់មុខសម្រាប់គំនូរឧស្សាហកម្ម

**មាត្រា ១០៥.-**

ការធ្វើអាជីវកម្មដោយបុគ្គលដទៃទៀត ដែលមិនមែនជាម្ចាស់លើគំនូរ ឧស្សាហកម្មដែលបានចុះបញ្ជីរួច ហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានការយល់ព្រមពីម្ចាស់ដើម ។

**មាត្រា ១០៦.-**

ក្នុងន័យនៃច្បាប់នេះ ការធ្វើអាជីវកម្មលើគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយ គឺការផលិត ការលក់ ឬការនាំចូលវត្ថុទាំងឡាយដែលបង្កើតឡើងដោយគំនូរឧស្សាហកម្មនោះ ។

**មាត្រា ១០៧.-**

សិទ្ធិទទួលបានពីការចុះបញ្ជីគំនូរឧស្សាហកម្ម មិនអនុវត្តទៅលើសម្ភារៈ ដែលបានដាក់តាំងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើទីផ្សារក្រៅព្រះរាជាណាចក្រកម្ពុជាដោយម្ចាស់ ឬដោយមានការយល់ព្រមពីម្ចាស់គំនូរឧស្សាហកម្មនោះទេ ។

# សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

**មាត្រា ២០.-**

សិទ្ធិសីលធម៌របស់អ្នកនិពន្ធមានបីចំណុចដូចខាងក្រោម :

ក- អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចពីរបៀប និងពេលវេលានៃការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ព្រមទាំងបែបបទគ្រប់គ្រងការផ្សព្វផ្សាយ ។

ខ- អ្នកនិពន្ធមានសិទ្ធិកំណត់ឱ្យគេទទួលស្គាល់ឈ្មោះ ឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយសាធារណជន ។

គ- អ្នកនិពន្ធមានសិទ្ធិជំទាស់នូវគ្រប់រូបភាពនៃការបំផ្លើស ឬការកាត់ចោលខ្លឹមសារ ឬការកែប្រែខ្លឹមសារជាហេតុធ្វើឱ្យខូចកិត្តិយសឬកេរ្តិ៍ឈ្មោះខ្លួន ។

**មាត្រា ២១.-**

សិទ្ធិបេតិកភណ្ឌ ជាសិទ្ធិប្រកបអាជីវកម្មរបស់អ្នកនិពន្ធលើ ទ្រព្យជាស្នាដៃរបស់ខ្លួនតាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈ និងការបង្កើតស្នាដៃបន្ត ។

# ៣.វិសាលភាពនៃសិទ្ធិផ្ដាច់មុខ

I. អ្នកទទួលសិទ្ធិផ្ដាច់មុខជាអ្នកមានសិទ្ធិធ្វើអាជីវកម្មនៅក្នុងទីតាំងផ្ដាច់មុខ លើទំនិញដែលទទួលសិទ្ធិ។ គ្មានអ្នកណាមានសិទ្ធិក្នុងការយកទំនិញសុទ្ធ ឬទំនិញដូចគ្នា ដែលមានម៉ាកដូចឬសញ្ញាសំគាល់ស្រដៀងគ្នាក្នុងទីតាំងផ្ដាច់មុខឡើយ។

II. សិទ្ធិផ្ដាច់មុខនាំឲ្យម្ចាស់សិទ្ធិអាចរៀបចំទីផ្សាររបស់ខ្លួនដោយដាក់ថ្លៃខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ។ គាត់អាចហាមមិនឲ្យទំនិញគាត់ត្រូវបានយកចូលទៅក្នុងតំបន់មួយផ្សេងទៀតទេ ដើម្បីកុំឲ្យមានការប្រកួតប្រជែងថ្លៃ រវាងទំនិញខ្លួនឯង។

III. ការនាំចូលទំនិញសុទ្ធ មកក្នុងតំបន់ ដែលមានសិទ្ធិផ្ដាច់មុខទទួលដោយអ្នកទទួលសិទ្ធិ គឺជា ការនាំចូលស្របគ្នា *Parallel Importation*

PICH & PARTNERS
Law & Intellectual Property

# ៤. សិទ្ធិទាំងនេះនឹងត្រូវផុត

គោលការណ៍ចរាចរណ៍ដោយសេរីនៃទំនិញ(សេវា)៖ ម្ចាស់កម្មសិទ្ធិបញ្ញាមិនអាចហាមឃាត់ការធ្វើចរាចរដោយតតិយជនបានឡើយ នៅក្នុងករណីខាងក្រោមត្រូវបានបំពេញ៖

- ការដាក់លក់ទំនិញ៖ លក្ខណៈនៃទំនិញ? ~~ទំនិញសាក Tester?~~
- លើដែនដីមួយ (National, Regional & International Exhaustion)
- ដោយមានការព្រមព្រៀងពីម្ចាស់សិទ្ធិ
- **នេះគឺជាការផុតសិទ្ធិ (Exhaution of Right)**
- ចំណាំ៖ សិទ្ធិអ្វីដែលផុត?
- វាមិនមែនជាការផុតរលត់សិទ្ធិទាំងអស់ទេ តែជាការផុតរលត់សិទ្ធិធ្វើអាជីវកម្ម ឬចរាចរនៃផលិតផល (Commercialisation/free circulation) តែប៉ុណ្ណោះ។

PICH & PARTNERS
Law & Intellectual Property

# ទម្រង់នៃការផុតសិទ្ធិផ្តាច់មុខ តាមវិសាលភាពនៃដែនដី

*ការផុតសិទ្ធិផ្តាច់មុខលើដែនដីមួយ (National, Regional & International Exhaustion) អាស្រ័យលើ តើប្រទេសនាំចូល(country of importation) ជ្រើសរើសយកការផុតសិទ្ធិបែបណា៖ A country of importation can choose to apply:*

- The concept of ***national exhaustion*** does not allow the IP owner to control the commercial exploitation of goods put on the domestic market by the IP owner or with his consent. However, the IP owner (or his authorized licensee) could still oppose the importation of original goods marketed abroad based on the right of importation.
- The concept of ***regional exhaustion***, the first sale of the IP protected product by the IP owner or with his consent exhausts any IP rights over these given products not only domestically, but within the whole region, and parallel imports within the region can no longer be opposed based on the IP right.
- The concept of ***international exhaustion***, the IP rights are exhausted once the product has been sold by the IP owner or with his consent in any part of the world.

(See: http://www.wipo.int/sme/en/ip_business/export/international_exhaustion.htm)

# ការផុតសិទ្ធិក្នុងកម្រិតជាតិ National Exhaustion



# ការផុតសិទ្ធិក្នុងកម្រិតតំបន់ Regional Exhaustion



# ការផុតសិទ្ធិក្នុងកម្រិតអន្តរជាតិ international Exhaustion



# ការផុតសិទ្ធិម៉ាក

គ- សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជី ម៉ាកនឹងមិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកនោះទេ ។

# ការផុតសិទ្ធិប្រកាសនីយប័ត្រតក្កកម្ម

**មាត្រា ៤៤.-**

សិទ្ធិដែលបានប្រគល់តាមរយៈប្រកាសនីយបត្រតក្កកម្មមិនអនុវត្តចំពោះ :

ក- សកម្មភាពពាក់ព័ន្ធនឹងសម្ភារៈ ដែលបានដាក់តាំងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើទីផ្សារក្រៅព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ ប្រកាសនីយបត្រតក្កកម្ម ឬដោយមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម

ខ- ការប្រើប្រាស់សម្ភារៈនៅលើអាកាសយាន យានយន្តផ្លូវគោក ឬនាវារបស់ប្រទេសដទៃ ដែលចូលចតជាបណ្ដោះអាសន្ន ឬចូលចតដោយឧបទ្ទវហេតុ ក្នុងដែនអាកាស ដែនគោក ឬដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា

# ការផុតសិទ្ធិគំនូរឧស្សាហកម្ម

ការធ្វើអាជីវកម្មដោយបុគ្គលដទៃទៀត ដែលមិនមែនជាម្ចាស់លើគំនូរ ឧស្សាហកម្មដែលបានចុះបញ្ជីរួច ហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានការយល់ព្រមពីម្ចាស់ដើម ។

**មាត្រា ១០៦.-**

ក្នុងន័យនៃច្បាប់នេះ ការធ្វើអាជីវកម្មលើគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយ គឺការផលិត ការលក់ ឬការនាំចូលវត្ថុទាំងឡាយដែលបង្កើតឡើងដោយគំនូរឧស្សាហកម្មនោះ ។

**មាត្រា ១០៧.-**

សិទ្ធិទទួលបានពីការចុះបញ្ជីគំនូរឧស្សាហកម្ម មិនអនុវត្តទៅលើសម្ភារៈ ដែលបានដាក់តាំងនៅលើទីផ្សារ នៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើទីផ្សារក្រៅព្រះរាជាណាចក្រកម្ពុជាដោយម្ចាស់ ឬដោយមានការ

# សូមអរគុណ

MERCI

PICH & PARTNERS
Law & Intellectual Property